# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ មេសា ឆ្នាំ ២០១៤
# និងទិសដៅការងារ ខែ ឧសភា ឆ្នាំ ២០១៤

(ពីថ្ងៃទី២៥/០៣/២០១៤ ដល់ ២៥/០៤/២០១៤)

ដោយផ្អែកលើផែនការសកម្មភាពអនុវត្តទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ត្រីមាសទី២ ឆ្នាំ២០១៤ និងទិសដៅការងារដែលបានដាក់ចេញកាលពីខែមីនា ឆ្នាំ ២០១៤ កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់បំពេញបេសកកម្មមួយចំនួន ដើម្បីរួមចំណែកអនុវត្ត " គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព"របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈនិងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋទទួលបានលទ្ធផលដូចខាងក្រោម ។

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍របស់អង្គភាពអនុវត្តន៍ច្បាប់ រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន, ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត, កងរាជអាវុធហត្ថរាជធានី-ខេត្ត ដែលបានរាយការណ៍ពីលទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា សកម្មភាពចរាចរជួញដូរ និងប្រើប្រាស់គ្រឿងញៀន បានកើតមាននៅរាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, កណ្តាល, តាកែវ, កំពង់ស្ពឺ, កំពង់ឆ្នាំង, កំពង់ចាម, សៀមរាប, ស្ទឹងត្រែង, ព្រះវិហារ, រតនគិរី, កំពត, បាត់ដំបង, បន្ទាយមានជ័យ, ពោធិ៍សាត់, កំពង់ធំ, ក្រចេះ និង ខេត្តមណ្ឌលគិរី ។ ជាការកត់សំគាល់ នៅក្នុងខែមេសានេះ កងកម្លាំងរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ បង្ក្រាបបាន ៣ ករណីធំៗ ។

- ករណីទី១ មន្ទីរប្រឆាំងគ្រឿងញៀន បានសហការជាមួយកម្លាំងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ដែលប្រចាំការនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បង្ក្រាបករណីដឹកជញ្ជូនគ្រឿងញៀនប្រភេទ កូកាអ៊ីនរាវជិត ៥ គីឡូក្រាម ពីប្រទេសប្រេស៊ីល ឆ្លងកាត់ប្រទេសអារ៉ាប់រួម ម៉ាឡេស៊ី ចូលមកកម្ពុជា ។ សកម្មភាពនេះ ធ្វើឡើងដោយបណ្តាញរបស់ក្រុមឧក្រិដ្ឋជនជាស្ត្រីជនជាតិរុស្ស៊ី ។
- ករណីទី២ បង្ក្រាបដោយកម្លាំងរបស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដោយបានចាប់យក មេតំហ្វេតាមីន ICE និងសារធាតុញៀនមួយចំនួនផ្សេងទៀត សរុបជិត ១ គីឡូក្រាម ។
- ករណីទី៣ បង្ក្រាបដោយកម្លាំងរបស់ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង ដោយបានចាប់យកមេតំហ្វេតាមីន ICE ជិត ១ គីឡូក្រាម ។

ដោយឡែក នគរបាលនាយកដ្ឋានប្រឆាំងបទល្មើសសេដ្ឋកិច្ច នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានសហការ ជាមួយកម្លាំងនៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល ចាប់យកសារធាតុគីមីផ្សំជាច្រើនមុខមានចំនួនប្រមាណជាង ៣០ តោន និងឃាត់ខ្លួនជនជាតិ ចិន ១ នាក់ ។

## II. អំពីការងារដឹកនាំ និង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ***១. អំពីការងារដឹកនាំ***

ឯកឧត្តម ឧបនាយករដ្ឋមន្រ្តី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំ និងដឹកនាំបញ្ហាលើការងារជាគោលសំខាន់ៗ រួមមាន ៖

**ក- អំពីគោលការណ៍ណែនាំ និងដឹកនាំបញ្ហា**

ឯកឧត្តមឧបនាយករដ្ឋមន្រ្តី បានណែនាំដល់អគ្គលេខាធិការ ឲ្យ ៖

- ពិនិត្យ និងរៀបចំកែសម្រួលសមាសភាពអ្នកគ្រប់គ្រងមណ្ឌលបណ្តោះអាសន្ន សម្រាប់អប់រំ បន្សាបព្យាបាលអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ ។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន និងក្រសួងទេសចរណ៍ ដើម្បីអប់រំ បង្ការ ទប់ស្កាត់និងបង្ក្រាបឲ្យបានសកម្មថែមទៀតនូវផលិតផល ស៊ីហ្សា និង បារីអេឡិចត្រូនិច ។
- ជំរុញក្រសួងសុខាភិបាល ក្នុងការរៀបចំបញ្ជីឈ្មោះទីកន្លែងផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ជាមូលដ្ឋាន (CBTx) នៅតាមរាជធានី-ខេត្ត ពិសេសជំរុញការផ្តល់សេវានេះនៅរាជធានីភ្នំពេញ ។
- ជំរុញក្រសួងសុខាភិបាល ក្នុងការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមប៉ុស្តិ៍សុខភាពក្នុងពន្ធនាគារ ។
- បើកវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពជំនាញ ដល់មន្រ្តីអនុវត្តន៍ច្បាប់នៅថ្នាក់ក្រោមជាតិចាប់ពីថ្នាក់ខេត្ត រហូតដល់ ថ្នាក់ប៉ុស្តិ៍រដ្ឋបាលមូលដ្ឋាន ។
- បើកវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពជំនាញ ក្នុងការប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀនតាមគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ។

**ខ- អំពីលិខិតបទដ្ឋានគតិយុត្តិ**

ឯកឧត្តម ឧបនាយករដ្ឋមន្រ្តី បានណែនាំអគ្គលេខាធិការ ឲ្យ ៖

- ជំរុញការរៀបចំអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- សហការជាមួយសាលាបណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីកែសម្រួលខ្លឹមសារឯកសារបណ្តុះបណ្តាលសម្រាប់មន្រ្តីអនុវត្តន៍ច្បាប់ ស្តីពីយុទ្ធសាស្រ្តប្រកបដោយប្រសិទ្ធភាព ក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន ។

### ***២. អំពីលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន***

ផ្តើមចេញពីគោលការណ៍ដឹកនាំរបស់ ឯកឧត្តម ឧបនាយរដ្ឋមន្រ្តី ប្រធាន អ.ជ.ប.គ.ញ ក៏ដូចជាផែនការ

អនុវត្តទិសដៅការងារ ដែលបានដាក់ចេញកាលពីខែមីនា ឆ្នាំ២០១៤ កន្លងទៅ អគ្គលេខាធិការដ្ឋាន បានបន្តអនុវត្ត វិធានការពហុវិស័យទទួលបានលទ្ធផលដូចខាងក្រោម :

### ២.១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

ក្រសួង-ស្ថាប័នជាសមាជិក និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយក្នុងកម្មវិធីប្រចាំថ្ងៃ សប្តាហ៍ ខែ, ការអប់រំតាមសហគមន៍ និងការបណ្តុះបណ្តាលក្រុមជនបង្គោល ទទួលបានលទ្ធផល ដូចមានក្នុងឧបសម្ព័ន្ធទី១ ។

**ដោយឡែក** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បាន :

- ផ្តល់កិច្ចសម្ភាសន៍តាមកម្មវិធី សភាអ៊ីនធឺណែត នៅស្ថានីយទូរទស្សន៍ CTN និង CNC (ជំនួសក្រសួងសុខាភិបាលដែលអវត្តមាន) ក្រោមប្រធានបទ "ការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន"។
- ផ្តល់ការគាំទ្រដល់សមាគមយុវជនខ្មែរ បន្តបើកវគ្គបណ្តុះបណ្តាល ការសម្តែងរឿងខ្លី ការចងក្រងក្លឹបយុវជន សកម្មភាពអប់រំរបស់ក្លឹបយុវជន ការចុះប្រមូលព័ត៌មាន/ទិន្នន័យ និងសិក្ខាសាលាស្តីពី "ការលើកកម្ពស់ការចូលរួមរបស់យុវជន ក្នុងការអប់រំបង្ការគ្រឿងញៀន និងគ្រឿងស្រវឹង" តាមវិទ្យាល័យ ឃុំ/សង្កាត់ នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប និង ខេត្តបន្ទាយមានជ័យ សម្រាប់ឆ្នាំ២០១៤ ។
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីជួយធ្វើសកម្មភាពអប់រំផ្សព្វផ្សាយស្តីពីបញ្ហាគ្រឿងញៀន នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី ឆស័ក ព.ស ២៥៥៨ ។
- ពិនិត្យលើសំណើសុំអនុញ្ញាតបន្តការអនុវត្តកម្មវិធី ម្ហូល/ស៊ីរ៉ាំង នៅរាជធានីភ្នំពេញ របស់អង្គការខាន់ណា ។
- ពិនិត្យលើរបាយការណ៍ឆ្នាំ២០១៣ របស់សមាគមយុវជនខ្មែរ ដែលបានធ្វើសកម្មភាពបណ្តុះបណ្តាលដល់យុវជននៅតាមវិទ្យាល័យ និងសហគមន៍ ស្តីពីការអប់រំបង្ការគ្រឿងញៀន គ្រឿងស្រវឹង និងថ្នាំជក់ (មានយុវជនចូលរួម **៤.៣០២** នាក់) ។
- សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តព្រះវិហារ, ខេត្តព្រះសីហនុ, ខេត្តសៀមរាប, អគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ជាតិ, ទូរទស្សន៍ហង្សមាស ក្នុងការបញ្ជ្រាបសកម្មភាពអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈការប្រគំតន្ត្រីស្រុកស្រែ ការប្រគំតន្ត្រីទេសចរណ៍របស់ក្រុមហ៊ុន ស្មាតម៉ូបាល សរុបមានមហាជនចូលរួមប្រមាណ **៦៩.៧០២** នាក់ ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន នៅតាមសហ-គមន៍ និងការងារបណ្តុះបណ្តាលក្រុមជនបង្គោល ដែលបានអនុវត្តដោយក្រសួង-ស្ថាប័ន ព្រមទាំងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន **៥** គឺ ខេត្តបាត់ដំបង, ព្រះសីហនុ, កំពង់ស្ពឺ, ស្វាយរៀង និង ខេត្តក្រចេះ នៅក្នុងខែមេសា ឆ្នាំ២០១៤ នេះ មានមហាជនចូលរួមប្រមាណ **១៦៣.៩១៥** នាក់ លើ ២៦៨.៨៤៤ នាក់ នៃខែមីនា ឆ្នាំ២០១៤ ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១ ។

### ២.២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

ក្នុងខែមេសានេះ មន្ត្រីអនុវត្តន៍ច្បាប់បានបន្តយកចិត្តទុកដាក់ចូលរួមសហការបង្ក្រាបបទល្មើសគ្រឿងញៀនគ្រប់ប្រភេទ សំដៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម :

### ក. ការងារបង្ក្រាបបទល្មើសគ្រឿងញៀន

- បទល្មើសគ្រឿងញៀន ដែលបង្ក្រាបបាន សរុប ***១០៣ ករណី*** លើ ៩៧ ករណី នៃខែមីនា ឆ្នាំ ២០១៤
- ជនសង្ស័យ ដែលបានឃាត់ខ្លួន សរុប ***២៣២*** នាក់ លើ ២៤៩ នាក់ នៃខែមីនា ឆ្នាំ២០១៤

  ក្នុងចំនួនបទល្មើសគ្រឿងញៀនទាំង ***១០៣ ករណី*** និង ជនសង្ស័យទាំង ***២៣២ នាក់*** ខាងលើគឺ :

  - ✓ បទល្មើសគ្រឿងញៀន បង្ក្រាបដោយនគរបាល មាន ***៧៣ ករណី***, ជនសង្ស័យ ***១៧៩ នាក់*** (ស្រី ២៩ នាក់)
  - ✓ បទល្មើសគ្រឿងញៀន បង្ក្រាបដោយកងរាជអាវុធហត្ថ ***៣០ ករណី***, ជនសង្ស័យ ***៥៣ នាក់*** (ស្រី ៨ នាក់)

- ក្នុងចំនួនជនសង្ស័យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដែលបានឃាត់ខ្លួនទាំង ២៣២ នាក់ ខាងលើ មាន ៣ សញ្ជាតិ គឺ ខ្មែរ ២២៨ នាក់ (ស្រី ៣៤ នាក់), វៀតណាម ៣ នាក់ (ស្រី ២ នាក់), រុស្ស៊ី ១ នាក់ (ស្រី) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូង រាជធានី-ខេត្ត ។
- **វត្ថុតាងគ្រឿងញៀនចាប់យក រួមមាន** មេតំហ្វេតាមីន WY ៧៥,០៧ ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ (ICE) ១.៥២៣,៤៣ ក្រាម, អ៊ិចស្តាស៊ី ១០,០៤ ក្រាម, កូកាអ៊ីន ៤.៩៦៣,២០ ក្រាម, កេតាមីន ៧៩,៥០ ក្រាម, ដើមកញ្ឆា ៣០០ ដើម, សារធាតុសង្ស័យគ្រឿងញៀន ១៧៩,០៣ ក្រាម ។
- ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន បានចាប់យករួមមាន ម៉ូតូ ៤២ គ្រឿង, រថយន្ត ២ គ្រឿង, ប្រាក់កម្ពុជា ១២.៣៩១.៨០០ រៀល, ប្រាក់ថៃ ១០០ បាត, ប្រាក់វៀតណាម ១.១០០.០០០ ដុង, ប្រាក់អាមេរិក ២.០៨៦ ដុល្លារ, ប្រាក់ចិន ១០ យ័ន ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២ ។

  ដោយឡែក ជនសង្ស័យចាប់តាមដីកា មាន ៤ ដីកា = មនុស្ស ៤ នាក់ (ប្រុស) ជនជាតិខ្មែរ ។

### ខ. ការត្រួតពិនិត្យ និងគ្រប់គ្រងសារធាតុគីមីផ្សំ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឲ្យនាំចូលនៅក្នុង ខែមេសា ឆ្នាំ២០១៤ នេះ មានដូចខាងក្រោម :

- សារធាតុគីមីចម្រុះ ចំនួន ៤.១២៨.៣៧២,៥ គ.ក្រ និង ១ លីត្រ
- វត្ថុធាតុដើម និងឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ចំនួន ១ គ.ក្រ ៧៦ ក្រាម ១.១០៣ មិល្លីក្រាម ១២៥ mcg ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២ ។

### គ. ការងារកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តន៍ច្បាប់នានា និងតុលាការរាជធានី-ខេត្ត នៅក្នុងខែមេសា ឆ្នាំ២០១៤ នេះ សរុបចំនួន ៨៨ ករណី =១០៦ សំណាក ។ ក្នុងនោះ **:**

- សំណាកវិជ្ជមានសារធាតុញៀន មាន ១០៤ សំណាក គឺ :

មេតំហ្វេតាមីន ICE ៨០ សំណាក = ៧៧ %　　មេតំហ្វេតាមីន WY ១៦ សំណាក = ១៥ %
កញ្ឆា ១ សំណាក = ១ % កេតាមីន ១ សំណាក = ១ % MDMA ៤ សំណាក = ៤ %
ឌីយ៉ាហ្សេប៉ាម　២ សំណាក = ២ %

- សំណាកអវិជ្ជមានសារធាតុញៀន ២ សំណាក = ២ %

## ២.៣. ការកាត់បន្ថយគ្រោះថ្នាក់ និងការព្យាបាល ស្តារនីតិសម្បទា ផ្តល់ទិជ្ជាជីវៈ និងសមាហរណកម្ម

- ***កម្មវិធីកាត់បន្ថយគ្រោះថ្នាក់***
  - ✓ បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ លើកទី៣ ដើម្បីកែសម្រួល "ឯកសារបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន (សៀមរាបថ្ងៃទី២៦/៤-០១/៥/ ២០១៤)។
  - ✓ បានចុះហត្ថលេខាអន្តរស្ថាប័ន លើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តកម្មវិធីបង្ការមេរោគអេដស៍និងគ្រឿងញៀន (ក្រសួងសុខាភិបាល, អង្គការ FHI360, សាកលវិទ្យាល័យកាលីហ្វ័រនីញ៉ា សាន់ហ្វ្រាន់ស៊ីស្កូ សហរដ្ឋអាមេរិក ដើម្បីអនុវត្តកម្មវិធីនេះនៅក្នុងរាជធានី-ខេត្ត ចំនួន ១០ ក្នុងប្រទេសកម្ពុជា ។
  - ✓ បានរៀបចំឯកសារ គោលនយោបាយ និងគោលការណ៍ណែនាំសម្រាប់ការអនុវត្តកម្មវិធី ម្ជុល/ស៊ីរ៉ាំង នៅកម្ពុជា ។
  - ✓ បានចូលរួមជាសហប្រធានកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការសិក្សាអនុវត្តកម្មវិធីបង្ការ សមាហរណកម្មជំងឺអេដស៍ និងគ្រឿងញៀនកម្ពុជា (០៤/៤/ ២០១៤) ។

- ***ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន***
  - ✓ បានរៀបចំរបាយការណ៍ស្តីពី កម្មវិធីព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ជាមូលដ្ឋាននៅកម្ពុជា តាមការស្នើសុំរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន នៃអង្គការសហប្រជាជាតិ ។

## ២.៤. ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់

### ការងារក្នុងប្រទេស

- បានរៀបចំកិច្ចប្រជុំស្តីពី ការត្រួតពិនិត្យគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន (គម្រោង PATROL) នៅច្រកទ្វារអន្តរជាតិ ដូង ខេត្តបាត់ដំបង និង ច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ (០៨-១១/៤/ ២០១៤ ដែលមានមន្ត្រីចូលរួម ចំនួន ២០ រូប) ។

### ការងារក្រៅប្រទេស

- បានចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់ទៅចូលរួមសិក្ខាសាលាស្តីពី កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀនតាមបណ្តោយព្រំដែនកម្ពុជា-ថៃ (ខេត្តចាន់ថាបូរី ២៦-២៨/៣/២០១៤)។

### ២.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសជិតខាង

- បានចូលជាសមាជិកនៅក្នុងគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម និងចាត់តាំង ប្រធាន-អនុប្រធាន និងសមាជិកចូលរួមនៅក្នុងអនុគណៈកម្មការទី ៤ នៃគណៈកម្មាធិការជាតិ ។

### ២.៦. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិ

- បានចូលរួមក្នុងកិច្ចប្រជុំបណ្តាប្រទេសម្ចាស់ជំនួយ (Mini Dublin Group) នៅស្ថានឯកអគ្គរាជទូតជប៉ុន ប្រចាំនៅកម្ពុជា (ថ្ងៃទី០២/៤/២០១៤) ។

### ២.៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ដើម្បីពង្រឹង និងពង្រីកលទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រពហុវិស័យរបស់អាជ្ញាធរជាតិឲ្យមានប្រសិទ្ធភាព អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បាន :

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងសមត្ថភាពការងារប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន តាមគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន (២៨/៤/២០១៤) ។
- ជំរុញការរៀបចំអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែឧសភា ឆ្នាំ២០១៤

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការ អ.ជ.ប.គ.ញ នឹងបន្តអនុវត្តទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

### ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. ស្នើសុំទៅក្រសួងអប់រំ យុវជន និងកីឡា ផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធី សភាអ៊ីនធឺ-ណែត នៃស្ថានីយទូរទស្សន៍ CTN និង CNC ស្តីពី ការទទួលខុសត្រូវលើការងារផ្សព្វផ្សាយអប់រំដល់សិស្សានុសិស្ស និងបុគ្គលិកសិក្សា ស្តីពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន (២៨/៥/២០១៤) ។

១.២. ចូលរួមក្នុងវគ្គបណ្តុះបណ្តាលជនបង្គោលសម្រាប់បណ្តាញការងារសហគមន៍ ចំនួន ៨៩ រូប នៅក្នុងឃុំពីររបស់ខេត្តកំពង់ចាម នាថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៤ ។

១.៣. ត្រៀមចូលរួមធ្វើបទឧទ្ទេសនាមក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌ ចំពោះបទល្មើសពិសេសចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១.៤. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន និងការបង្ការទប់ស្កាត់ការប្រើប្រាស់ ការធ្វើអាជីវកម្មផលិតផល ស៊ីហ្សា និង បារីអេឡិចត្រូនិច ទៅក្នុងការប្រគំតន្ត្រីផ្សព្វផ្សាយ ពាណិជ្ជកម្ម និងវេទិកានានា នៅតាមរាជធានី-ខេត្ត ទូទាំងប្រទេស ។

១.៥. ត្រួតពិនិត្យ តាមដានការអនុវត្តកម្មវិធីអប់រំពីបញ្ហាគ្រឿងញៀន និងគ្រឿងស្រវឹង ដែលអនុវត្តដោយ

សមាគមយុវជនខ្មែរ នៅតាមវិទ្យាល័យ-អនុវិទ្យាល័យ និងនៅតាមសហគមន៍ ក្នុងរាជធានីភ្នំពេញ, ខេត្តបាត់ដំបង, បន្ទាយមានជ័យ និងខេត្តសៀមរាប ។

១.៦. ចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតនាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន នៃក្រសួងសុខាភិបាល នៅថ្ងៃទី០៥/៥/២០១៤ ។

១.៧. រៀបចំកម្មវិធីប្រឡងប្រណាំងការគូរគំនូរក្រោមប្រធានបទ យើងរួបរួមគ្នាប្រឆាំងគ្រឿងញៀន ។

១.៨. ត្រៀមរៀបចំទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ២០១៤ ។

១.៩. បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ និងវិស័យឯកជន ដើម្បីជំរុញការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយនានា ។

១.១០. បន្តជំរុញការងារបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមក្រសួង-ស្ថាប័ន រោងចក្រ សហគ្រាស និងនៅតាមសហគមន៍ ។

## ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. សហការសម្របសម្រួលជាមួយមន្ទីរប្រឆាំងគ្រឿងញៀន, ការិយាល័យប្រឆាំងគ្រឿងញៀនរាជធានី-ខេត្ត និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងការស្រាវជ្រាវរកខ្សែរយៈទាក់ទង ដែលនៅសេសសល់ពាក់ព័ន្ធនឹងករណីធំៗដែលបង្ក្រាបបានកន្លងមក ។

២.២. ចាត់វិធានការដោះស្រាយចំពោះសារធាតុគីមី ចំនួន ១៨.៩០០ គ.ក្រ ដែលបានចុះទៅពិនិត្យដល់ទីកន្លែងរក្សាទុក នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

២.៣. បន្តជំរុញក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពី ការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ។

## ៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

៣.១. ចូលរួមឧទ្ទេសនាមក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ពង្រឹងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមប្រឈមខ្ពស់តាមរយៈកម្មវិធីដៃគូសហគមន៍ នៅខេត្តចំនួន ៥ គឺ រតនគិរី, មណ្ឌលគិរី, ក្រចេះ, ព្រះវិហារ, ឧត្តរមានជ័យ ។

៣.២. ជំរុញក្រសួងសុខាភិបាល ក្នុងការរៀបចំបញ្ជីឈ្មោះកន្លែងផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ជាមូលដ្ឋាន (CBTx) នៅតាមរាជធានី-ខេត្ត និងជំរុញការផ្តល់សេវានេះ នៅរាជធានីភ្នំពេញ ។

៣.៣. ជំរុញក្រសួងសុខាភិបាល ក្នុងការអនុវត្តកម្មវិធី មេតាដូន នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ។

៣.៤. រៀបចំកែសម្រួលសមាសភាពគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ ។

## ៤. ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តច្បាប់

៤.១. ចាត់បញ្ជូនមន្ត្រីជំនាញ ៦០ រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងកិច្ចសហប្រតិបត្តិការរបស់មន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀនរវាងកម្ពុជា-ថៃ (ធ្វើនៅខេត្តណាខនណាយុក និង ខេត្តព្រះណាកនស៊ីអាយុទ្យា ១៩-២៣/៥/២០១៤) ។

៤.២. ត្រៀមដឹកនាំប្រតិភូរបស់អគ្គលេខាធិការដ្ឋាន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ ។

៤.៣. ត្រៀមរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ របស់គណៈកម្មការដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែន កម្ពុជា-ឡាវ ។

៤.៤. រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់នានា នៅតាមខ្សែបន្ទាត់ព្រំដែន ។

៤.៥. បន្តរៀបចំបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ តាមម៉ាស៊ីនកុំព្យូទ័រ (CBT) ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

៥.១. ចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់ ចំនួន ៣០ រូបទៅចូលរួមក្នុងកិច្ចប្រជុំ ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ ពីថ្ងៃទី១៨-២៤ ខែឧសភា ឆ្នាំ២០១៤ នៅប្រទេសថៃ (នៅប្រទេសថៃ) ។

៥.២. ជំរុញកិច្ចប្រជុំឲ្យបានទៀងទាត់ រវាងបណ្តាខេត្តនិងខេត្តជាប់ព្រំដែន កម្ពុជា-ថៃ / កម្ពុជា-វៀតណាម / កម្ពុជា-ឡាវ ។

៥.៣. ត្រៀមរៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ ទៅប្រទេសវៀតណាម និងឡាវ ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និង អន្តរជាតិ

៦.១. រៀបចំទទួលដំណើរទស្សនកិច្ចរបស់ប្រតិភូប្រទេសណេប៉ាល់ ដែលអញ្ជើញមកសិក្សាស្វែងយល់ពីការងារត្រួតពិនិត្យគ្រឿងញៀន នៅកម្ពុជា (ថ្ងៃទី១៥-២២/៥/២០១៤) ។

៦.២. ចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ MoU នៃបណ្តាប្រទេសហត្ថលេខីនៃមហាអនុតំបន់ទន្លេមេគង្គស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅទីក្រុងប៉េកាំង ប្រទេសចិន (២៧-៣១/៥/២០១៤) ។

៦.៣. ត្រៀមលក្ខណៈរៀបចំកិច្ចប្រជុំនានា ក៏ដូចជាត្រៀមទៅចូលរួមរាល់កិច្ចប្រជុំ សន្និសីទ សិក្ខាសាលាទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៧.១. បន្តរៀបចំកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.២. រៀបចំបោះពុម្ពសៀវភៅរបាយការណ៍លទ្ធផលនៃការសិក្សាថ្នាក់ជាតិស្តីពី "ការធ្វើអង្កេតរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍, ឥរិយាបថប្រឈមគ្រោះថ្នាក់ និងការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿង

ញៀន នៅកម្ពុជា ឆ្នាំ២០១២" ។

៧.៣. រៀបចំវគ្គបណ្តុះបណ្តាលពីអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីគ្រឿងញៀន ដល់មន្ត្រីរាជការនៃក្រសួងសមាជិក របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.៤. រៀបចំវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដល់ មេឃុំ ចៅសង្កាត់ នគរបាលប៉ុស្តិ៍រដ្ឋបាល មន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធ នៅតាមរាជធានី-ខេត្ត ។

**អគ្គលេខាធិការ**

**ចម្លងជូន**
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ
  "ដើម្បីជូនជ្រាប"
- ក្រសួង សមាជិក អ.ជ.ប.គ.ញ
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
- នាយកដ្ឋាន សរុប ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីមុខការ"
- ឯកសារ